# មជ្ឈមណ្ឌលឯកសារកម្ពុជា

*សម្ភាសន៍ជាមួយពូ សូត្រ សាំង ភេទប្រុស អាយុ៤៨ឆ្នាំ*

*មុខងារសម័យខ្មែរក្រហមៈ អ្នកយាមគុកក្រាំងតាចាន់*

*រស់នៅភូមិត្រពាំងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ*

*សម្ភាសន៍ដោយៈ ជួង សុភារិទ្ធ*

*ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤*

*សរុបៈ ១៩ទំព័រ*

*ភារិទ្ធៈ ដូចខ្ញុំបានជំរាបពូខ្លះៗហើយអំពីគោលបំណងរបស់ខ្ញុំក្នុងការចុះមកនេះ ។ ដើម្បីឲ្យពូយល់កាន់តែច្បាស់អំពីកន្លែងខ្ញុំថែមទៀត ខ្ញុំចង់ណែនាំ និងសួរនាំដូចថាជំនាន់ខ្មែរក្រហមធ្វើអី? ផ្លាស់ពីណាទៅណាអញ្ចឹង ។ តែខ្ញុំចង់ណែនាំពូឲ្យច្បាស់អំពីកន្លែងខ្ញុំ និងកម្មវិធីនឹងសិនណាស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា កន្លែងខ្ញុំមានសិក្សាពីរឿងរ៉ាវខ្មែរក្រហមធ្វើជាប្រវត្តិសាស្ត្រសំរាប់ក្មេងជំនាន់ក្រោយ ។ ទីពីរគឺប្រមូលព័ត៌មាន ដើម្បីធ្វើខាងផ្លូវច្បាប់ ពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយគោលដៅទាំងពីរគឺដើម្បីលើកកំពស់ការចងចាំនិងយុត្តិធម៌ ហើយទាំងពីរនឹងតំណាង ឲ្យការផ្សះផ្សាជាតិ និងមូលដ្ឋានគ្រឹះនៃច្បាប់នៅក្នុងប្រទេសកម្ពុជាយើង ។ គំរោងខ្ញុំសួរនេះសួរនូវ ហេតុការណ៍ដែលប៉ះពាល់ខាងផ្លូវចិត្ត ។ ដោយសារអង្គការខ្ញុំគ្មានជំនាញខាងផ្លូវចិត្ត អង្គការខ្ញុំបានសហការណ៍ជាមួយអង្គការអន្តរវប្បធម៌ផ្លូវចិត្តសហគមន៍ (ធីភីអូ) គឺដើម្បីចងក្រងព័ត៌មាន ភាពរន្ធត់ទុកជាប្រវត្តិសាស្ត្រ ប្រសិនសំណួរសួរនេះរកឃើញ ការប៉ះពាល់ខាងផ្លូវចិត្ត ហើយខាងអង្គការសុខភាពផ្លូវចិត្តសហគមន៍រកឃើញគេនឹងចុះមក ជួបពូដើម្បីផ្តល់ជាប្រឹក្សា ផ្តល់ថ្នាំព្យាបាលដើម្បីកុំឲ្យពូចេះតែនឹកគិត រំខានដល់ការងារប្រចាំថ្ងៃរបស់ពូ ។ គំរោងនេះមានរយៈពេល២ឆ្នាំ ហើយត្រូវធ្វើនៅខេត្តបី ។ ទីមួយគឺកណ្តាល ធ្វើនៅស្រុកកណ្តាលស្ទឹងដោយសារស្រុកនេះស្ថិតនៅតំបន់ក្តៅ កន្លែងមានគុករណ្តៅសាកសព ដូចជានៅគុកសង់ទន្លេបាទី ។ ទីពីរគឺខេត្តតាកែវ ហើយយើងយកតែស្រុកត្រាំកក់ទេព្រោះស្រុកនេះមានគុកក្រាំងតាចាន់ មានកន្លែងសម្លាប់ ។ ប្រជាជន*

ដែលរស់នៅ កន្លែងទាំងអស់នេះអាចជួបប្រទះហេតុការណ៍អ្វីមួយឈឺចាប់ គេចាប់ឃុំឃាំង ធ្វើបាប ហើយការណ៍នេះធ្វើឲ្យប៉ះពាល់អារម្មណ៍យើង ។ ខេត្តមួយទៀតគឺកំពត ។ ខេត្តនេះអត់មានទីតាំងសម្ងាប់អីទេតែជាកន្លែងអតីតខ្មែរក្រហមផ្តាច់ខ្លួន ហើយការជួយនេះមិនមែនជួយតែអ្នកខ្មែរក្រហមទេ ជួយដូចគ្នា ពិសេសអតីតខ្មែរក្រហមដូចពូ និងពួកផ្តាច់ខ្លួន ។ ពួកនឹងអាចជួបការមានរបួស នឹងធ្វើឲ្យមានបញ្ហាផ្លូវចិត្ត ។ ខ្ញុំចង់បញ្ជាក់ថាបញ្ហាសុខភាពផ្លូវចិត្ត មនុស្សគ្រប់រូបអាចជួបប្រទះដូចគ្នា ។ យើងមិនអាចកំណត់ថានរណា មានបញ្ហាទេ លុះត្រាតែយើងចុះមកសួរនាំ ។ ប្រសិនពូមានចម្ងល់សូមសួរ ខ្ញុំប្រាប់ ។

សាំង: ខ្ញុំចង់ជំរាបថាមកសួរតែបញ្ហាផ្លូវចិត្តទេ ។ ខ្ញុំជំរាបថាពីមុនខ្ញុំមានប៉ះពាល់បញ្ហាផ្លូវចិត្តមែន ដោយសារទីមួយខ្ញុំមានឈ្មោះស្អុយអាសោចខ្ញុំមានអារម្មណ៍ច្រើនមិនដឹងថាគេយកខ្ញុំទៅធ្វើទុក្ខធ្វើទោសដូចកាលពីមុន ខ្ញុំដេកគិតពិចារណាច្រើន២-៣ឆ្នាំមុន ។ ពេលនោះយើងរស់នៅមិនដែលលួចទេ តែដល់យើងចូលវង់អ្នកលួចគេថាយើងលួចបាត់ទៅហើយ ។ អារម្មណ៍ខ្ញុំវិលវល់ ក្រោយមក ខ្ញុំខំជំរះកាត់បន្ថយថាបើយើងពីមុនយើងប្តេជ្ញាជូនរដ្ឋថាបើរដ្ឋយកយើងធ្វើអីធ្វើទៅ ធម្មតា ។ ខ្ញុំខំប្រឹងបើមិនប្រឹងយើងមិនបាន ។

ភារិទ្ធ: ពូថាមានអារម្មណ៍ខ្លាចគេចាប់មានពេលណា?

សាំង: ១៩៨២-១៩៨៥ រហូតដល់កាត់បន្ថយបានខ្លះបច្ចុប្បន្ននេះ ។ ១៩៩៣ ខ្ញុំរស់នៅធម្មតាវិញ ។ ខ្ញុំរកស៊ីបន្តិចបន្តួច ហើយសុខសប្បាយរហូត ។

ភារិទ្ធ: ការកាត់ទោសខ្មែរក្រហមពូធ្លាប់បានឮ?

សាំង: បានត្រឹមឮ ។ គេផ្សាយតាមវិទ្យុថាកាត់ទោសខ្មែរក្រហម តែមិនដឹងថាកម្រិតណាទេ ។ អ្នកដឹកនាំអីទេ តាម៉ុក ឮតែឈ្មោះមិនដែលឃើញមុខ ។

ភារិទ្ធ: ខ្ញុំចង់បញ្ជាក់ថាការកាត់ទោសខ្មែរក្រហម តាមច្បាប់តុលាការចំរុះគេមានបំណងកាត់ទោសតែមេដឹកនាំធំៗរបបខ្មែរក្រហមទេពីឆ្នាំ១៩៧៥-១៩៧៩ ក្រោយមកទៀតគេមិនកាត់ទេ ។ ពី១៩៧៥-៧៩ ធ្វើឲ្យមនុស្សស្លាប់ច្រើន ។ បើគេរកឃើញគេយកអ្នកទាំងនោះទៅកាត់ទោស ។ មកដល់ឥឡូវខ្ញុំក៏មិនដឹងថានរណាគេយកទៅកាត់ទោសដែរ ។ ថ្មីៗនេះមានតាម៉ុក និងឌុចជាប់គុក ។ ស្គាល់ឌុចទេ?

សាំង: ឌុច ណា?

ភារិទ្ធ: ឌុច មេគុកទួលស្លែង?

សាំង: អត់ស្គាល់ទេ។

ភារិទ្ធ: ឌុច នឹងជាប់គុក ក្រៅពីនោះដូចជាខៀវ សំផន, អៀង សារិ, នួន ជា អីអត់ជាប់ទេ។ ដើរហើរសេរីពេញស្រុកខ្មែរដដែល។ ប៉ុល ពត ស្លាប់ហើយ និងប្រពន្ធគាត់ ខៀវ ប៉ុណ្ណារី និង អៀង ធារិទ្ធ នៅរស់ដែរ។ ដល់តុលាការរកឃើញ ខាងខ្ញុំគ្រាន់តែប្រមូលព័ត៌មានដូចខ្ញុំជំរាបពីខាង ដើមគឺមានព័ត៌មានខាងផ្លូវច្បាប់ និងខាងប្រវត្តិសាស្ត្រ។ អញ្ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ពីប្រវត្តិដើម និងក្រោយមកទើបខ្ញុំចាប់ផ្ដើមសួរសំណួរ។

សាំង: ចាំមិនអស់ទេ។ ពេលយុវវ័យ ឥឡូវក្មេចច្រើនដែរជិត៣០ឆ្នាំហើយ។ កាលឆ្នាំ១៩៧០ នៅជាយុវជន អត់មានកងទេ ក្រោយមក១៩៧២មានកងយុវជន។ គេយកឪពុកទៅជាប់នៅ ២០៤ គេយកទាំងគ្រួសារ មួយពូជទៅ២០៤។ ខ្ញុំនៅលាយបូ, ជ្រៃ, ត្រាំកក់ តាកែវ។

ភារិទ្ធ: ម៉េចបានគេប្រមូលពូទៅចូលកង?

សាំង: មកពី២០៤ ឆ្នាំ១៩៧៣គេដាក់កងយុជន។

ភារិទ្ធ: ម៉េចបានគេយកទៅ២០៤?

សាំង: គេយកឪពុកទៅ។ គេចោទថាគាត់ជាកិញ្ចលន់ នល់។ ខាងបដិវត្តគេចាប់គាត់ទៅ២០៤ ហើយគេយកទាំងពូជ នៅឃុំអូសារាយ ខេត្តតាកែវ។ ក្រោយមកគាត់ស្លាប់នៅ២០៤ ម្ដាយខ្ញុំ ស្លាប់ពេលខ្ញុំអាយុ៦ឆ្នាំ។ បងខ្ញុំឈ្មោះសន នៅត្រពាំងថ្នាន គុស តាកែវ។ បងស្រីមួយនៅភូមិ ជ្រៃ ឃុំគុស ត្រាំកក់ ខេត្តតាកែវ។ ខ្ញុំនៅនេះភូមិត្រពាំងថ្ម គុស ខេត្តតាកែវ។ បងប្រុសបង្អស់ នៅខាងពោធិសាត់ ភូមិត្រពាំងជង។ ប្រុស៣ ស្រី១។ ស្រីនៅលាយបូរយើងនេះ។ ក្រោយមកឆ្នាំ១៩៧៣ គេឲ្យខ្ញុំមកធ្វើស្រែវិញ សក់ក្បាលជ្រុះអស់នៅនោះតំបន់ចាញ់ អត់មានថ្នាំសង្កូវ មានតែថ្នាំអាចម៍ទន្សាយ។ ស្របក់នឹងមានគ្រូពេទ្យគេឲ្យថ្នាំគ្រាប់ផ្កាឈូក ពុះចែកជា៣ បានលេប ហើយជារហូត។ បាន១៩៧៣មកនៅភូមិវិញនៅកងយុវជន។ ក្រោយមកគេឲ្យនៅខាងយុវជនឃុំនៅ

ដឹកព្រែក ប្រឡាយ ។ ឆ្នាំ១៩៧៣ជិតចូល១៩៧៤គេបំពាក់អាវុធឲ្យត្រៀមប្រយុទ្ធជាមួយទាហានលន់ នល់ ។

ភារិទ្ធៈ ប្រយុទ្ធនៅណា?

សាំងៈ នៅម្តុំវត្តអង្គធ្លក ស្រុកត្រាំកក់ដែរ ឃុំរំចង់ ។ មានរបួសដែរខ្ញុំ ។ គេបញ្ជាឲ្យបាញ់ ចេះតែបាញ់ ។

ភារិទ្ធៈ មានឃើញគេរបួសទេ?

សាំងៈ មាន ។ ពេលប្រយុទ្ធនៅត្រសេកជ្រុំ វានៅក្នុងភូមិ ខ្ញុំត្រូវរបួសពេលជិតចូល១៩៧៤ ។

ភារិទ្ធៈ ឪពុកពូបាត់ដោយសារអ្វី? គេយកទៅសម្លាប់ ឬយ៉ាងម៉េច?

សាំងៈ អត់ដឹង ។ ពេល១៩៧២អត់ដឹងរឿងគាត់សោះ បាត់រហូតដល់សព្វថ្ងៃ ។ ដល់១៩៧៣គេឲ្យមកវិញ ធ្វើស្រែជំនាន់លន់ នល់ ។

ភារិទ្ធៈ មានឮពាក្យខ្មែរក្រហម?

សាំងៈ អត់ ។ ឮតែពាក្យបដិវត្ត ។

ភារិទ្ធៈ ខ្មែរក្រហម និងបដិវត្តខុសគ្នាម៉េច?

សាំងៈ ខ្មែរក្រហមឮពេលបែក១៩៧៩នេះហើយទេ ។

ភារិទ្ធៈ ចុះក្នុងរបបប៉ុល ពត៧៥-៧៩មានឮ?

សាំងៈ អត់ដែរ ។ ប៉ុល ពត ឮពេលយួនចូលហើយទេ ។ យួនទាន់បានឮថាប៉ុល ពត ។

ភារិទ្ធៈ ពូរៀបរាប់ពេលមានរបួស?

សាំងៈ ខ្ញុំទៅតាមពេទ្យកងគេ របួសស្រាល អំបែងជាប់ គេព្យាបាលតាមកង ហើយគេឲ្យចូលកងយុវជនវិញ ។ គេឲ្យនៅខាងរកម្ហូប សេដ្ឋកិច្ច ។

ភារិទ្ធៈ កងយុវជនអី?

សាំងៈ ឈ្លបឃុំ នៅដល់ឆ្នាំ៩៧៥ បែកទីក្រុង ។ គេឲ្យមកនៅត្រៀមតាមចាប់ព្រំ សាន ។ ត្រៀមនៅភ្នំលិច ទំនប់តាសែត ។ ដល់ឆ្នាំ១៩៧៧ មានវិបត្តិឈឺ ខ្ញុំទុកកាំភ្លើងនៅមាត់គ្រង់សេ ហើយអ្នកដើររុងយកកាំភ្លើងទៅបាត់ ។ គេចាប់យកមកអប់រំនៅចំការដូងឃុំគុស ត្រាំកក់ដែរ ។ កាលនោះអត់មានប្រជាជនទេ ។

ភារិទ្ធៈ ពេលបែក១៩៧៥នៅណា?

សាំង: នៅត្រៀមចាប់ព្រំ សាន់ដល់១៩៧៧ ។ ដល់ចុង១៩៧៨ទៅនៅដាងទង ត្រាំកក់ដែរ ។ ដល់១៩៧៨គេឲ្យទៅនៅមន្ទីរក្រាំងតាចាន់ ។

ភារិទ្ធ: មកប៉ុន្មាននាក់?

សាំង: ៦នាក់ ។

ភារិទ្ធ: នរណាខ្លះ?

សាំង: អាសាន់, ឌុច, ស៊ីម, ទូច, ខ្វុ, អ្នក ។

ភារិទ្ធ: មានអ្នកនៅរស់?

សាំង: នៅព្រំដែនមួយ ។ អាខ្លះនៅកំពង់ស្ពឺ ។ អាឌុច នៅត្រាំកក់ដែរ ។ មន្ទីរគេមាន៨នាក់ តាឈៀង, មឿង, ចេង, ពេញ, អាន់, ឌុច ៧នាក់ ។

ភារិទ្ធ: គេបែងចែកម៉េចការគ្រប់គ្រង?

សាំង: គេចែកជាផ្នែក៧នាក់នៅមន្ទីរ ។ ៦នាក់នៅខាងការពារ ។ មេគេតាអាន់ ។

ភារិទ្ធ: រៀបរាប់មន្ទីរធ្វើអ្វី? សន្តិសុខធ្វើអី?

សាំង: គេគ្រប់គ្រងអ្នកទោស បើកងយោធាការពារនៅខាងក្រៅ ។ ដីមន្ទីរគេមានសិទ្ធិគ្រប់គ្រង ។

ភារិទ្ធ: មន្ទីរនរណាខ្លះ?

សាំង: តាឈៀង, ម៉ឺន, អាន់, ពេញ, មឿង, ចេង នៅខាងមន្ទីរគេ ។ គេបញ្ជាខាងយោធាបាន ។

ភារិទ្ធ: មាននរណារស់?

សាំង: អត់ដឹងដែរ ។ មិនដែលជួបនរណារស់ស្លាប់ទេ តាចេង, មឿន ឮថាស្លាប់ហើយ ។

ភារិទ្ធ: ចុះខាងពូវិញ?

សាំង: នៅតែ២នាក់ ។ នៅតែអាឌុច និងខ្ញុំ ។

ភារិទ្ធ: ឌុច នៅណា?

សាំង: មិនដឹងភូមិអី ខាងជើងអង្គតាសោម ដូចជាឃុំតាភេម ។ ឥឡូវថាទៅរកស៊ីនៅព្រំដែន ។

ភារិទ្ធ: មានតែ២ក្រុម?

សាំង: ២ក្រុម ។ ប្រធានធំមានអាន់, ចេង, ពេញ ។

ភារិទ្ធ: ចុះតាឆេន?

សាំង: នៅវត្តមុនទេ ។ អត់ដឹងទេ ។

ភារិទ្ធ: នៅក្រាំងតាចាន់ប៉ុន្មានឆ្នាំ?

សាំង: ១ឆ្នាំ ។

ភារិទ្ធ: ពូជួយប្រាប់ខ្ញុំធ្លាប់ឃើញគេសម្លាប់ទេ?

សាំង: វាមាន២កន្លែង ។ មានរបងក្នុង ក្រៅ ប៉ែកខាងត្បូងគេបិទជិតជិនាន់ហ្នឹង ។ គេឲ្យការពារជ្រុងខាងជើង ការពារមិនឲ្យប្រជាជនដើរជិតទេ គឺកន្លែងនោះគេសម្លាប់ យើងដឹងម៉ង ។ អារម្មណ៍យើងដឹងថាគេធ្វើឃាត ។ ១-២ខែមានម្តង ។

ភារិទ្ធ: មានកន្លែងសម្លាប់មនុស្សមានពូសួរសម្រែក ឬឃើញ?

សាំង: បើឃើញអត់ទេ ។ បើពូគេវៃសួរចម្លើយពូមែន គេធ្វើទារុណកម្ម ពូស្រែកអូយៗ អត់ទេ គេវៃបន្តិចឲ្យឆ្លើយ ។

ភារិទ្ធ: ពេលពូមានអារម្មណ៍ម៉េច?

សាំង: ខ្លាចចិត្តម៉ង បងគេបងយើង សម្រែកបងប្អូនយើង គេវៃដំប្រំធាក់ចេញជាចម្លើយ ។

ភារិទ្ធ: មានភ័យខ្លាច?

សាំង: មិនហ៊ានមើលមុខប្រធានទេ ។ ខ្លាចអំណាចគេ ។ ឧទាហរណ៍ គេហៅប្រើ សាំង មកនេះ យើងទៅឈរស្ងៀម ។ គាត់ថាយក១០នាក់នេះទៅវែកដីដំបូក ការពារ៣នាក់ រួចហើយយកមកប្រគល់ឲ្យគេវិញ ។ យប់ឡើងយាម ២-៣ម៉ោងយាមតាមបញ្ជាគេទៅ ។

ភារិទ្ធ: មានជួបសាកសពគេសម្លាប់ហើយ?

សាំង: មិនដែលបានជួប ។ គេអត់ឲ្យយើងចូលខាងក្នុង ។ ដីគេប្រហែល៧០-៨០ម៉ែត្រ មានរបងក្រៅ និងរបងលួសមួយជាន់ទៀតខាងក្នុង ។ ក្រៅធំ ក្នុងតូច ។ ដីខាងត្បូងគេអត់ឲ្យយើងចូលទេ ពួកមន្ទីរគេបាន ។ បើកន្លែងផ្សេងៗទៀតយើងចូលបាន ផ្លូវដើរដើមស្វាយចូលបាន ។ មានអ្នកទោសគេបញ្ជូនមកពីភូមិពីឃុំអីយើងចាំទទួលយកហើយបញ្ជូនចូលទៅគេមកទទួលពីយើងទៀត ។ ខាងក្នុងគេអ្នកបើក ។

ភារិទ្ធ: អ្នកទោសនាំមកពីខាងណា?

សាំង៖ ខេត្តតាកែវ មានស្រុកគេ ។ កងវត់ចោលផ្លូវ មានវិបត្តិខាងភេទខាងអី ខ្លះណាជ្រុលជ្រួស ហួសកម្លាំងតែងមានសំដី ។ អ្នកធ្វើការជាមួយចេះតែសួរនាំ មានអីចេះតែហូបទៅ មកតាមឃុំស្រែរនោង, ញ៉ែងញ៉ង, គុស ។

ភារិទ្ធ៖ ខ្ញុំឮថាអ្នកដែលគេយកមកសម្លាប់នៅក្រាំងតាចាន់ភាគច្រើនប្រជាជនថ្មី?

សាំង៖ មិនប្រកាន់ថ្មីចាស់ទេ ឲ្យតែខុស ។ ខុសភាគច្រើនពួកមូលដ្ឋាន ចេញធ្វើការងារជាមួយខ្ញុំ ភាគច្រើនមូលដ្ឋាន ។ ខ្លះខុសថាផ្ដួលលាន់មិនដែលភ្លៀង ។

ភារិទ្ធ៖ បានន័យថាម៉េច?

សាំង៖ ឮតែយួនចូល ហើយមិនដែលឃើញ ។ ចំណុចបំបះបំបោរ គេចោទថាបះបោរ គេយក មកដាក់នេះ រៀនសូត្រ កសាង ។

ភារិទ្ធ៖ គេដឹកអីមកអ្នកទោស?

សាំង៖ មកដើរធម្មតា ដើរមក ។ ជួនកាលចង ជួនកាលអត់ ។ ខ្ញុំខស្សាហ៍បើកទ្វារឲ្យគេ ឃើញ មានចងដែរ ។

ភារិទ្ធ៖ មានស្រី ប្រុស?

សាំង៖ មានស្រី ប្រុស ។

ភារិទ្ធ៖ មានដែលការរំលោភចំពោះអ្នកទោសស្រី?

សាំង៖ មិនដែលដឹងការរំលោភ ។ ថាមិនបានព្រោះមិនដែលឃើញ ថាទៅវាខុស ។ ពេល វៀតណាមចូលខ្ញុំរត់ចេញទៅស្រែក្នុង ខេត្តកំពត ។ ចេញទៅទៀតខាងពោធិ៍សាត់រហូតឆ្នាំ យើងជិតធ្វើស្រែ យួនទាន់បានមកវិញ ។

ភារិទ្ធ៖ ម្ដុំណា?

សាំង៖ លាច, ដំណាក់បាក់ចញ្ចៀន ចេញទៅនៅគ្រង រួចទៅដំណាក់ស្ដេច ។

ភារិទ្ធ៖ រត់ទៅជាមួយប្រជាជន?

សាំង៖ ទៅជាមួយប្រជាជន ។

ភារិទ្ធ៖ មានជួបហេតុការណ៍តាមផ្លូវ?

សាំង៖ មានបាញ់គ្នា ដេញពីក្រោយ រត់បណ្ដើររហូត មិនដឹងខាងណាខាងណី ។ មកស្រុកវិញឆ្នាំ ១៩៧៩ ខែ៨ ធ្វើស្រែ ។

ភារិទ្ធៈ ពេលមកវិញមានជួបហេតុការណ៍អីទេ?

សាំងៈ ខាងរដ្ឋអំណាចគេសាកសួរខ្ញុំដែរ។ ខ្ញុំថាខ្ញុំនៅនឹងមែន តែការងារវែងច្រំផាក់អត់មានទេ។ ប្រជាជននៅនេះក៏ដឹងដែរ ដើររកត្រី រកអី រកស៊ីធម្មតារហូតដល់សព្វថ្ងៃនឹង។

ភារិទ្ធៈ ពូរៀបរាប់ពីប្រវត្តិពូចប់ហើយ ឥឡូវខ្ញុំចង់សួរពីអារម្មណ៍ទាក់ទងនឹងព្រឹត្តិការណ៍ពូធ្លាប់ជួបប្រទះ? ពូមានធ្លាប់ជួបប្រទះការខ្វះម្ហូបអាហារ ឬទឹក?

សាំងៈ និយាយពីណាមក។ សម័យខ្មែរក្រហមខ្ញុំអត់យល់ទេ ព្រោះវាមានតែពី១៩៧៩មកទេ។

ភារិទ្ធៈ ពី១៩៧០-១៩៧៥ធ្លាប់ជួបអត់?

សាំងៈ ខ្វះខាតច្រើនណាស់បង។ ខ្វះខាតជាងគេឆ្នាំ៧២-៧៣ ខ្វះខ្លាំង។

ភារិទ្ធៈ ចុះ៧៥-៧៩?

សាំងៈ ខ្វះផ្សាល់ខ្លួនម៉ង ក្លួចពុលរាប់អាទិត្យ។

ភារិទ្ធៈ ពី៧៥-៧៩មានអត់ថ្នាំព្យាបាល?

សាំងៈ មានពេល៧៣ ឈឺគ្រុនចាញ់។

ភារិទ្ធៈ ចុះមកដល់ខ្មែរក្រហម?

សាំងៈ គ្រុនចាញ់មួយសារទៀត។

ភារិទ្ធៈ មានខ្វះជំរកស្នាក់នៅ?

សាំងៈ ឆ្នាំ៧១-៧២ព្រោះយើងរត់ពីខាងលិចរហូតដល់ទៅ២០៨។

ភារិទ្ធៈ មានធ្លាប់ជាប់ឃុំឃាំង?

សាំងៈ ឆ្នាំ៧៧មានគេឃុំឃាំង។ គេកសាងមួយឆ្នាំ គេយកទៅរៀនសូត្រ អត់មានឃុំអីទេ។

ភារិទ្ធៈ ធ្លាប់ឃើញគេចាប់ឃុំ?

សាំងៈ អត់។ ពេលនៅក្រាំងតាចាន់ឃើញ។

ភារិទ្ធៈ ធ្លាប់មានរបួសធ្ងន់?

សាំងៈ រងរបួសធ្ងន់នៅសមរភូមិញឹកញាប់ណាស់។ របួសធ្ងន់ឆ្នាំ៧៣ អាបេវ៉ែ។ របួសបាញ់គ្នាទម្លាក់យន្តហោះ ត្រូវនៅតាកែវ ជិតដាច់៧៣ចូល៧៤។

ភារិទ្ធៈ ធ្លាប់ប្រយុទ្ធញាប់?

សាំងៈ រង្វើលទេ។ សង្គ្រាមឈ្លបមិនធំដំទេ។

ភារិទ្ធៈ  មានដែលគេអប់រំឲ្យផ្លាស់ប្តូរគំនិត?

សាំងៈ  អត់ទេ ។

ភារិទ្ធៈ  ចង់និយាយផ្លាស់ប្តូរគំនិតចាស់គឺរិល?

សាំងៈ  អត់ដែលមាន ។ ដឹងខ្លួនឯងតែម្តង ។

ភារិទ្ធៈ  មានដែលពុ ឃើញការចាប់រំលោភ?

សាំងៈ  អត់ដែលមាន ។

ភារិទ្ធៈ  នៅឯកោតែឯង?

សាំងៈ  អត់ដែលទេ ។

ភារិទ្ធៈ  ធ្លាប់ជួបហេតុការណ៍បិះនឹងស្លាប់ខ្លួន?

សាំងៈ  ជួប ។

ភារិទ្ធៈ  ពេលណា?

សាំងៈ  ឆ្នាំ១៩៧៩ ពេលរត់ចេញពីខេត្ត ស្រុកយើងទៅ ។

ភារិទ្ធៈ  ដោយសារអី?

សាំងៈ  ជីវភាពមិនគ្រប់ ដាច់ជីវភាពអត់អីហូប ។

ភារិទ្ធៈ  ចុះធ្លាប់គេបំបែកចេញពីសមាជិកគ្រួសារ?

សាំងៈ  អត់មានទេ ។

ភារិទ្ធៈ  ចុះធ្លាប់ធ្វើការងារគ្រឡប់ពី៤២០វិញ?

សាំងៈ  អូ២០៤ រត់ពេលយើងទៅកងដាច់ពីគ្រួសារ ឪពុកម្តាយ ។ គេបង្ខំឲ្យយើងចូលកងយុវជន គេបង្ខំឲ្យយើងទៅ ។

ភារិទ្ធៈ  ចុះធ្លាប់មានក្រុមគ្រួសារ មិត្តភក្តិគេសម្លាប់?

សាំងៈ  ពុមាន ។ ំបាត់ទាំងពូជ ។ គេសម្លាប់ទាំងពូជ ។

ភារិទ្ធៈ  សម្លាប់នៅណា?

សាំងៈ  សម្លាប់នៅតាផាន់ លាយបូ ។

ភារិទ្ធៈ  គេយកទៅសម្លាប់?

សាំងៈ  ខាងជើងវត្តតាលឿ នៅខាងជើងអន្លង់សោម សាលាអន្លង់ចំបក់ ។

ភារិទ្ធៈ គាត់ខុសអី?

សារិនៈ យួនចូល ។ គាត់អត់រត់ទេ គាត់នៅ ហើយកងទ័ពគេខ្លាំង បងប្អូនកុំទៅលិច អាពួកខ្មែរក្រហមចាប់គាត់សម្លាប់ចោល ។ កាលនោះច្របូកច្របល់គ្នា ។

ភារិទ្ធៈ ពូមានដែលជួបការសម្លាប់ខុសប្លែកពីធម្មតា?

សារិនៈ អត់ដែល ។

ភារិទ្ធៈ មានឃើញផ្សេងទៀត?

សារិនៈ អត់ ។

ភារិទ្ធៈ មានដែលវង្វេងក្នុងព្រៃ?

សារិនៈ មាន ពេលបែក៧៩ ។

ភារិទ្ធៈ មានដែលរងទារុណកម្ម?

សារិនៈ គ្មានទេ ។ បើជាសំដី គេបញ្ចិតបញ្ចៀងដូចថាយើងធ្លាប់នៅក្រាំងតាចាន់ សមតែវ៉ៃចោល ។

ភារិទ្ធៈ ពូមានធ្លាប់ជួបហេតុការណ៍គួរឲ្យរន្ធត់ ឬមានគ្រោះថ្នាក់?

សារិនៈ គ្មានទេ ។

ភារិទ្ធៈ កាលពីរបបខ្មែរក្រហម៧៥-៧៩តើហេតុការណ៍ណាដែលរន្ធត់ហើយឈឺចាប់បំផុត?

សារិនៈ ពេលនៅក្រាំងតាចាន់ និងពេលនៅសហករណ៍ តាមកង រន្ធត់ចិត្តបំផុត ។

ភារិទ្ធៈ មានបងប្អូនពូគេយកទៅសម្លាប់នៅក្រាំងតាចាន់ដែរ?

សារិនៈ មាន ។

ភារិទ្ធៈ ពេលណា?

សារិនៈ ឆ្នាំ៧៨ ។

ភារិទ្ធៈ ពូនៅនឹង?

សារិនៈ នៅ ។

ភារិទ្ធៈ មានជួបគាត់?

សារិនៈ បានជួប ។

ភារិទ្ធៈ ពូយល់ឃើញម៉េចដែរ?

សាំង៖ ពិតជាស្លាប់ តែមិនដឹងធ្វើម៉េច

ការិទ្ធ៖ ខែណា?

សាំង៖ អត់ចាំដែរ ពេលជិតស្គួង ធ្លាក់ភ្លៀងសាប ឆ្នាំ៧៨ ។ រន្ធត់ចិត្តឃើញកូនមីងទៅហើយមិនដឹងធ្វើម៉េច ទៅនិយាយគេខ្លាចដោយទាំងខ្លួន ។

ការិទ្ធ៖ ខ្ញុំចង់សួរបន្តទៀតក្រែងពូធ្លាប់រងរបួសត្រូវក្បាលអី ។ សំណួរទីមួយពូមានដែលធ្លាប់លង់ទឹកអីដែរ?

សាំង៖ អត់ដែលទេ ។

ការិទ្ធ៖ មានដែលថប់ដង្ហើម?

សាំង៖ មានពេលយប់ ។

ការិទ្ធ៖ ឆ្នាំណា?

សាំង៖ រាល់ថ្ងៃនឹង ។

ការិទ្ធ៖ មានត្រូវដែលគេវាយត្រូវក្បាល?

សាំង៖ មាន ។ ពេលរៀនណាមវៃ យើងសិស្សគេគ្រូឆ្នាំ៨៣-៨៤ ។

ការិទ្ធ៖ ទៅរៀននៅណា?

សាំង៖ នៅព្រៃនគរ ។ ខ្ញុំរត់ចូលកាំបូល ។

ការិទ្ធ៖ ធ្លាប់ដែលសន្លប់?

សាំង៖ មាន ។

ការិទ្ធ៖ ឆ្នាំណា?

សាំង៖ ដកធ្មេញសន្លប់ ។ ពេទ្យមកដាក់សេរ៉ូមឲ្យនៅផ្ទះ សន្លប់មួយយប់មួយថ្ងៃ ។

ការិទ្ធ៖ ខ្ញុំចង់សួរអំពីអារម្មណ៍ថ្មីៗនេះ ដើម្បីដឹងពីកម្រិត ។ ថ្មីៗនេះមានគិតជារឿយៗអំពីព្រឹត្តិការណ៍ឈឺចាប់?

សាំង៖ គ្មានទេ មួយអាទិត្យនេះ ។

ការិទ្ធ៖ មានដែលមានអារម្មណ៍ថាព្រឹត្តិការណ៍ជួបប្រទះកំពុងកើតឡើងថ្មីៗ?

សាំង៖ អត់ ។

ការិទ្ធ៖ មានដែលយល់សប្តិអាក្រក់?

សាំង៖ អត់ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍មិនរវល់មិនចង់ជួបអ្នកដទៃ?

សាំង៖ មាន ។ រកស៊ីមិនចង់ទាក់ទងបងប្អូនណា ជាប់ការងាររកស៊ី ។

ភារិទ្ធ៖ ខ្លាំង ឬតិច?

សាំង៖ ធម្មតា ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ពុំអាចរំភើបចិត្ត?

សាំង៖ អត់ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ភ្ញាក់ផ្អើល?

សាំង៖ អត់ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ពិបាកផ្ចង់គំនិតធ្វើអ្វីមួយ?

សាំង៖ មានដែរ តិចតួច ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ពិបាកដេក?

សាំង៖ ធម្មតា ។ ហូបច្រើនអត់ដេកលក់ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ប្រុងខ្លួនជានិច្ច?

សាំង៖ មានច្រើនដែរ ខ្លាចតែចោរលួចគោ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ឆាប់ខឹង?

សាំង៖ តិចតួច ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍ចង់ជៀសវាងព្រឹត្តិការណ៍គ្រៀមក្រំ?

សាំង៖ ចង់សតិអារម្មណ៍គ្រៀមក្រំ ។

ភារិទ្ធ៖ មានដែលមានអារម្មណ៍មិនអាចនឹកឃើញការឈឺចាប់?

សាំង៖ មាន ។ ភ្លេចច្រើន ជួនកាលភ្លេចនៅផ្សារគេប្រើទៅទិញអី ។

ភារិទ្ធ៖ ចង់និយាយថានឹកអត់ឃើញហេតុការណ៍ឈឺចាប់ជំនាន់ខ្មែរក្រហម?

សាំង៖ មានតិចតួច ។

ភារិទ្ធ៖ មានដែលមិនសូវចាប់អារម្មណ៍ការងាររាល់ថ្ងៃ?

សាំង៖ មានច្រើនដែរ ។

ភារិទ្ធៈ  មានអារម្មណ៍ថាគ្មានអនាគត?

សារំងៈ  មាន ខ្លាំងមែនទែន មិនដឹងយ៉ាងម៉េចទៅណារួច ។

ភារិទ្ធៈ  មានអារម្មណ៍ចង់ជៀសវាងការត្រៀមត្រំចិត្ត?

សារំងៈ  ចង់ឲ្យទូលាយ ចង់ខ្លាំង ។

ភារិទ្ធៈ  ពេលនឹកឃើញការឈឺចាប់មានដែលមានការរំភើបមួយរំពេច?

សារំងៈ  អត់ដែលមាន ។

ភារិទ្ធៈ  មានអារម្មណ៍ថាអ្នកដទៃមិនយល់ច្បាស់ពីអ្វីដែលកើតឡើង?

សារំងៈ  អត់ដែលមានទេ ។

ភារិទ្ធៈ  មានការពិបាកក្នុងការបំពេញការងារទេ?

សារំងៈ  លំបាក ។

ភារិទ្ធៈ  មានស្តីបន្ទោសខ្លួនឯងអំពីរឿងអតីតកាល?

សារំងៈ  មានខ្លាំង ។ ខ្លួនខុសហើយមិនដឹងថាកម្រិតដល់ប៉ុណ្ណឹង ។

ភារិទ្ធៈ  មានអារម្មណ៍ថាមិនចង់រស់នៅ?

សារំងៈ  មានច្រើនដែរអាណឹង ។ ខ្មាសគេ ។

ភារិទ្ធៈ  មានដែលអស់សង្ឃឹម?

សារំងៈ  មានដែរ បន្ទាប់បន្សំ ។

ភារិទ្ធៈ  មានអារម្មណ៍គួរឲ្យខ្មាស?

សារំងៈ  មាន ។ ខ្លាំងមែនទែន ។

ភារិទ្ធៈ  មានឆ្ងល់ថាហេតុអីបានជារឿងនឹងកើតឡើងចំពោះពូ?

សារំងៈ  មានអារម្មណ៍រាល់ថ្ងៃ ។

ភារិទ្ធៈ  មានគិតថាចង់ឆ្កួត?

សារំងៈ  អត់ទេ ។

ភារិទ្ធៈ  មានគិតថាមានតែពូម្នាក់គត់ដែលឈឺចាប់ក្នុងអតីតកាល?

សារំងៈ  អត់ទេ ។

ភារិទ្ធៈ  មានអារម្មណ៍ថាអ្នកដទៃសុទ្ធតែជាសត្រូវនឹងខ្លួន?

សារ៉ុង៖ មិនបានមួយរយភាគរយទេបង ។

ភារិទ្ធ៖ មានអារម្មណ៍ថាគ្មាននរណាម្នាក់គួរឲ្យទុកចិត្ត?

សារ៉ុង៖ គ្មាន ។

ភារិទ្ធ៖ ពេលដឹងពេលគេប្រាប់ឲ្យធ្វើអ្វីមួយហើយយើងនឹកអត់ឃើញសោះ?

សារ៉ុង៖ មាន ។

ភារិទ្ធ៖ ថ្មីៗនឹង?

សារ៉ុង៖ នឹងហើយ ។

ភារិទ្ធ៖ មានអារម្មណ៍ថាយើងត្រូវបែងភាគជា២មួយជាអ្នកតាមដាន មួយទៀតជាអ្នកធ្វើ?

សារ៉ុង៖ អត់ដែលមានទេ ។

ភារិទ្ធ៖ មានអារម្មណ៍ថានរណាម្នាក់ជាទីទុកចិត្តហើយបានក្បត់ចិត្ត?

សារ៉ុង៖ អត់ ។

ភារិទ្ធ៖ សំណួរតទៀតនេះមានការជាន់ជាមួយមុន តែដើម្បីឲ្យដឹងច្បាស់អំពីកម្រិតអារម្មណ៍ ។ សំណួរទី១គឺ ថ្មីៗនេះមានដែលភ័យខ្លាចទេ?

សារ៉ុង៖ មាន ។

ភារិទ្ធ៖ មានភ័យខ្លាចសព្វថ្ងៃ?

សារ៉ុង៖ មាន ។ ភ័យថាខ្លាចបាត់របស់ក្នុងផ្ទះយើង ។

ភារិទ្ធ៖ ភ័យខ្លាំង?

សារ៉ុង៖ ខ្លាំង ។

ភារិទ្ធ៖ ថ្មីៗនេះមានធុញទ្រាន់ខ្លាំង?

សារ៉ុង៖ មានខ្លាំង ។

ភារិទ្ធ៖ មានការជ្រួលជ្រាល ភ័យខ្លាច?

សារ៉ុង៖ មានញ័រសាច់ញាក់ខ្លួនមាន ។

ភារិទ្ធ៖ មានខ្លាំងដែរអត់?

សារ៉ុង៖ ខ្លាំង ។

ភារិទ្ធ៖ មានដែលមានបេះដូងដើរញាប់បុកដើមទ្រូង?

សាំង៖ មាន សំរាន្តមិនលក់ៗ ខ្លាំងៗ

ភារិទ្ធ៖ មានដែលញ័រខ្លួន?

សាំង៖ មានៗ គិតច្រើនញ័រសាច់ៗ

ភារិទ្ធ៖ មានអារម្មណ៍តឹងតែង?

សាំង៖ មាន ពេលដោះស្រាយអីមិនចេញៗ

ភារិទ្ធ៖ មានដែលឈឺក្បាល?

សាំង៖ មានៗ ថ្នាំមិនទាន់ចប់ផងរាល់ថ្ងៃៗ

ភារិទ្ធ៖ មានភ័យស្លន់ស្លោ?

សាំង៖ មានខ្លាំងៗ

ភារិទ្ធ៖ មានអារម្មណ៍រសាប់រសល់នៅមិនសុខ?

សាំង៖ មានៗ

ភារិទ្ធ៖ បន្ទាប់មកចង់សួរថាពូមានដែលមានអារម្មណ៍ថាស្មុក អស់កម្លាំង?

សាំង៖ មានៗ ខ្ជិលធ្វើការងារខ្លាំងដែរៗ

ភារិទ្ធ៖ មានដែលស្តីបន្ទោសខ្លួនឯង?

សាំង៖ មានដែរ ពេលនឹកឃើញកាលសម័យបោកប្រាស់ៗ

ភារិទ្ធ៖ មានដែលស្រែកយំ ងាយនឹងយំ?

សាំង៖ អត់មានៗ

ភារិទ្ធ៖ ពូដែលមានអារម្មណ៍អស់ការសប្បាយរួមដំណេក?

សាំង៖ មានៗ ជិត២ឆ្នាំហើយៗ

ភារិទ្ធ៖ ពូដែលមានអារម្មណ៍មិនសូវឃ្លាន?

សាំង៖ មាន ខ្លាំងដែរៗ

ភារិទ្ធ៖ ពូដែលមានអារម្មណ៍ពិបាកគេង?

សាំង៖ មានៗ ម៉ោង១-២ក៏មានដែរៗ

ភារិទ្ធ៖ ពូដែលមានអារម្មណ៍អស់សង្ឃឹមពីអនាគត?

សាំង៖ មានៗ

ភារិទ្ធៈ ពូដែលមានអារម្មណ៍ស្រងូតស្រងាត់?

សាំងៈ មានខ្លាំងដែរ ។ ស្រងូតស្រងាត់មិនដឹងធ្វើយ៉ាងម៉េច ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ឯកោម្នាក់ឯង?

សាំងៈ មានជាប្រចាំ ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ថាចង់សម្លាប់ខ្លួន?

សាំងៈ អត់ទេ ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ហាក់ដូចជាជាប់អន្ទាក់ទៅណាមិនរួច?

សាំងៈ មាន មធ្យម ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ព្រួយពីបញ្ហាផ្សេងៗ?

សាំងៈ មានខ្លាំង ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍អត់ចាប់អារម្មណ៍លើអ្វីទាំងអស់?

សាំងៈ អត់មានទេ ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ថាអ្វីទាំងអស់សុទ្ធតែលំបាក?

សាំងៈ មានខ្លាំង សុទ្ធតែលំបាក ។

ភារិទ្ធៈ ពូដែលមានអារម្មណ៍ថាខ្លួនឯងអត់តម្លៃ?

សាំងៈ មានមធ្យម ។

ភារិទ្ធៈ ឥឡូវចប់សំណួរពីអារម្មណ៍ហើយតែខ្ញុំចង់ដឹងពីគំនិតពូពីតុលាការ ការផ្សះផ្សាជាតិ ។ ពូមាន
ដែលឮអំពីដំណើរការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

សាំងៈ ពូតាមគេ វិទ្យុ ។

ភារិទ្ធៈ ឮពេលណា?

សាំងៈ មុនប្រូតនឹង ។ គេថាកាត់ទោសខ្មែរក្រហមថាមានកាត់ទោសខ្មែរក្រហម មិនចាំទេ ។

ភារិទ្ធៈ មានឮអីផ្សេងទៀត?

សាំងៈ ឮពីមាត់មួយទៅមាត់មួយ ។

ភារិទ្ធៈ ចង់ដឹងដែរ?

សាំងៈ ចង់ដែរ ។ កាសែត ទស្សនាវដ្ដីមិនដែលអានផង មិនយល់ច្បាស់ទេ ។

ភារិទ្ធៈ ពូមានពូអ្នកដឹកនាំកំពូលខ្មែរក្រហម?

សាំង: មានឈ្មោះតាម៉ុក ថាភូមិភាគ ។ ខ្មែរក្រហមពូពេល៧៩មកទេ គ្រាន់តែពូ មិនដែលដឹង ។

ភារិទ្ធៈ នរណាខ្លះស្លាប់បានដឹងទេ?

សាំង: អត់ដឹង អត់ចាប់អារម្មណ៍ការងាររអស់នឹង ។

ភារិទ្ធៈ ចុះប៉ុល ពតស្លាប់ដឹងទេ?

សាំង: ពូគេថាដែរ ។

ភារិទ្ធៈ ចុះអ្នកនៅរស់ នៅក្រៅឃុំ និងក្នុងឃុំរង់ចាំការកាត់ទោស?

សាំង: អត់ដឹង មិនដែលបានសិក្សាផង ។

ភារិទ្ធៈ ការនាំយកមេដឹកនាំខ្មែរក្រហមកំពូលៗទៅកាត់ទោសពូយល់ថាចាំបាច់ដែរឬទេ?

សាំង: ចាំបាច់លើរដ្ឋាភិបាល គិតម៉េចធ្វើតាមណឹងទៅ ។

ភារិទ្ធៈ អ៊ំផ្ទាល់សំខាន់ទេ?

សាំង: សំខាន់ណាស់ព្រោះពលរដ្ឋរាប់លាននាក់បាត់បង់ជីវិត ។

ភារិទ្ធៈ ការនាំយកមេដឹកនាំខ្មែរក្រហមកាត់ទោសវាជាការសងសឹក ឬជារឿងច្បាប់?

សាំង: ទេ វាជាការធ្វើឲ្យប្រជាពលរដ្ឋអស់ចិត្ត ។

ភារិទ្ធៈ ការពន្យាពេលកាត់ទោសមានប៉ះពាល់អារម្មណ៍ពូទេ?

សាំង: អត់មានទេ ។

ភារិទ្ធៈ ចុះក្រកាត់ទោសម៉េចដែរ?

សាំង: អត់មានទេ ។ អត់ស្តាយទេ ។

ភារិទ្ធៈ ពូថាចង់ឲ្យមានតុលាការ តែវាយូរ ពន្យាពេល តើមានប៉ះពាល់អារម្មណ៍ពូទេ?

សាំង: អត់ទេ ។ ទាំងគេទាំងខ្ញុំគឺវាប៉ះពាល់ កាត់ទោសគឺដើម្បីឲ្យប្រជាជនរងគ្រោះ លាងខ្លួនអ្នកដឹកនាំក្បត់ជាតិ យកជាតិខ្លួនឯងទៅជាន់ឈ្លី ។

ភារិទ្ធៈ ពូចង់ឲ្យកាត់ឆាប់?

សាំង: កាន់តែល្អ ។

ភារិទ្ធៈ ហេតុអី?

សាំង: កុំឲ្យមានអំពើនឹងទៀត ។

ភារិទ្ធៈ  តុលាការអាចកើតមានទេ?

សារំផៈ  អាចកើតមាន ប្រទេសនីមួយៗតែងតែមាន។

ភារិទ្ធៈ  ប្រសិនបើតុលាការដែលមានអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលបង្កើតឡើង តើពូគិតថាវាមានយុត្តិធម៌សំរាប់ពូទេ?

សារំផៈ  មិនអាចថាបាន នៅលើច្បាប់។

ភារិទ្ធៈ  ហេតុអី?

សារំផៈ  ដូចឥឡូវថាយុត្តិធម៌ តែយុត្តិធម៌នៅលើក្រដាស។

ភារិទ្ធៈ  ពាក្យយុត្តិធម៌ ចំពោះពូមានន័យថាម៉េច?

សារំផៈ  អត់ស៊ីសំណូកសូកប៉ាន់ ខុសដឹងខុសត្រូវដឹងត្រូវ ហ្នឹងយុត្តិធម៌។

ភារិទ្ធៈ  ពូយល់ម៉េចដែរការផ្សះផ្សារួមគ្នាវិញជាមួយអតីតខ្មែរក្រហម ដែលធ្លាប់ធ្វើបាបគ្រួសារពូ?

សារំផៈ  ខ្ញុំជាសតិអារម្មណ៍អត់មានទេចង់តែបង្កបង្កើតផលចិញ្ចឹមប្រពន្ធកូនខ្ញុំទេ។

ភារិទ្ធៈ  ប្រសិនអ៊ំបានដឹងនរណាម្នាក់បានសម្លាប់គ្រួសារអ៊ំកាលពីរបបខ្មែរក្រហម អ៊ំចង់សងសឹកទេ?

សារំផៈ  មាននៅរស់ តែខ្ញុំអត់មានចងពៀរ ចងកម្មទេ។

ភារិទ្ធៈ  ពាក្យចងកម្ម ចងពៀរមានន័យថាម៉េច?

សារំផៈ  ខ្ញុំសម្លាប់អ្នកនឹង កូនអ្នកនឹងមកចង់សម្លាប់កូនខ្ញុំវិញ ខ្ញុំអត់ចង់បានទេ។ អ្នកណាធ្វើ អ្នកនោះទទួលទៅ។

ភារិទ្ធៈ  ការបង្កើតតុលាការអាចប៉ះពាល់ដល់ការផ្សះផ្សាជាតិទេ?

សារំផៈ  ចំណុចហ្នឹងខ្ញុំអត់យល់ដែរ។

ភារិទ្ធៈ  ប្រទេសយើងកាន់ព្រះពុទ្ធសាសនា តើអាចជួយការផ្សះផ្សាជាតិខ្មែរទេ?

សារំផៈ  មានជំនឿសាសនាពីដូនតា ជឿជាក់លើគាត់ ហុចផលល្អលើយើង ធម្មតា។

ភារិទ្ធៈ  តើអាចជួយការផ្សះផ្សាជាតិខ្មែរទេ?

សារំផៈ  ជួយបង។

ភារិទ្ធៈ  ហេតុអី?

សាំងៈ ព្រោះសាសនាឲ្យមនុស្សមិនកាប់ចាក់គ្នាទេ ។

ភារិទ្ធៈ ពូយល់ម៉េចដើម្បីឲ្យប្រទេសយើងមានយុត្តិធម៌ ការផ្សះផ្សាជាតិពិតប្រាកដ?

សាំងៈ បំបាត់អំពើពុករលួយ អំពើហិង្សាជុំវិញគ្រួសារនីមួយៗ ។

ភារិទ្ធៈ ធ្វើម៉េចអាចបំបាត់បាន?

សាំងៈ ត្រង់ចំណុចនឹងខ្ញុំមិនហ៊ានសន្និដ្ឋានដែរ ។

ភារិទ្ធៈ ពូយល់ថាមានសន្តិភាពទេបើការឆក់ប្លន់ ញៀនស្រាតើយើងមានសន្តិភាពទេ?

សាំងៈ អត់ទេ ។

ភារិទ្ធៈ ធ្វើយ៉ាងណាដើម្បីកាត់បន្ថយ?

សាំងៈ កាត់អំពើយង់ឃ្នងលោភលន់ ហ្នឹងបាន ។

ភារិទ្ធៈ ពូមានដែលគេសួរនាំការឈឺចាប់ពីជំនាន់ខ្មែរក្រហម?

សាំងៈ កាលពីសម័យខ្មែរក្រហមគេសួរនាំ ។

ភារិទ្ធៈ ខ្ញុំចង់សួរថាពូមានដែលនិយាយប្រាប់នរណាម្នាក់?

សាំងៈ មានដែរ ធម្មតា ។

ភារិទ្ធៈ ពូយល់ថារឿងខ្មែរក្រហមគួរតែចងក្រងជាប្រវត្តិសាស្ត្រ?

សាំងៈ ត្រូវតែចងក្រង ដូចកូនខ្ញុំអត់ជឿទេ ។

ភារិទ្ធៈ ពូពេលបាននិយាយរឿងខ្មែរក្រហម ឈឺចាប់ប្រាប់ខ្ញុំតើពូមានអារម្មណ៍បានធូរស្បើយខ្លះដែរឬទេ?

សាំងៈ ធម្មតា និយាយហើយភ្លេចចោលទៅ អត់មានរំភើបអីត្រង់ណា ធម្មតា ។

ភារិទ្ធៈ បើយើងមិនដែលនិយាយសោះ ពេលនិយាយឈឺចាប់ តើបានធូរអត់?

សាំងៈ ធម្មតា អត់មានធូរទេ ។

ភារិទ្ធៈ ពេលនិយាយប្រាប់កូនចៅពូ ហើយអត់ជឿអញ្ចឹងតើពូយល់ថាគួរតែចងក្រងឲ្យរៀននៅតាមសាលាទេ?

សាំងៈ ត្រូវតែបញ្ចូល លំបាកយ៉ាងម៉េច សង្រ្គាមយ៉ាងម៉េច ដល់ឲ្យវាសិក្សាបានវាដឹងខ្លះ ។

ភារិទ្ធៈ ធ្វើម៉េចកុំឲ្យរបបខ្មែរក្រហមវិលមកវិញម្តងទៀត?

សាំងៈ ដល់យើងគៀកស្មាគ្នា កុំឲ្យវាត្រឡប់ក្រោយបាន ទើបយើងរស់ ។

ភារិទ្ធ: ចុះរាល់ថ្ងៃខ្មែរយើងមានសាមគ្គីឬនៅ?

សាំង: ខ្ញុំកោតសសើរបានរើខ្មែរក្រហមបាន ខ្លាំងណាស់លើពិភពលោកនេះគ្មានអ្នកស្មើទេ ។

ភារិទ្ធ: ខ្ញុំចង់សួរពូ១-២សំណួរទៀត ។ ពេលមានគេមកសួរនាំការលំបាកពីរបបខ្មែរក្រហមដែលពូធ្លាប់ឆ្លងកាត់តើពូយល់ម៉េចដែរ?

សាំង: គ្មានបញ្ហាអីទេ ។ សូម្បីកាលជំនាន់ប៉ុល ពត ខ្ញុំប្ដេជ្ញាជូនរដ្ឋ ឥឡូវរដ្ឋត្រូវការយកទៅចុះ ។ អត់មានតប់ប្រមល់ទល់ព្រះធោអីទេ ។

ភារិទ្ធ: ពេលពូមានការថប់អារម្មណ៍ បញ្ហាផ្លូវចិត្តពូធ្វើម៉េចដែរ?

សាំង: ខឹងខុស ខឹងខាត វាខូចខាតច្រើន ។

ភារិទ្ធ: វាមានប្រសិទ្ធិភាព?

សាំង: មាន ។ បើខ្ញុំខឹងខ្លាំង ខូចក៏ខ្លាំងដែរ ។

ភារិទ្ធ: ពូធ្លាប់ពិគ្រោះអាការៈរោគផ្លូវកាយផ្លូវចិត្តជាមួយគ្រូពេទ្យ?

សាំង: អត់ទេ ។ មានតែជាមួយប្ដីប្រពន្ធខ្ញុំ ។

ភារិទ្ធ: ពូមានអីចង់សំណូមពរចង់បញ្ជាក់បន្ថែម?

សាំង: ខ្ញុំអរគុណរាជរដ្ឋាភិបាល ។ ខ្ញុំមិនបានអីជូនរដ្ឋ កុំឲ្យតែរដ្ឋជូនខ្ញុំវិញ មានតែប៉ុណ្ណឹង ។

ភារិទ្ធ: ពូឈ្មោះអី?

សាំង: សូត្រ សាំង

ភារិទ្ធ: អាយុប៉ុន្មាន?

សាំង: ឆ្នាំវក ៤៤-៤៥ ។ ដូច៤៤ ឆ្នាំវក ។

ភារិទ្ធ: អរគុណអ៊ំច្រើន ។

ចប់